**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃ អង្គារ ៥រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ផែនការបោះផ្សាយលក់មូលបត្ររដ្ឋឆ្នាំ២០២២

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, បេឡាជាតិរបបសន្តិសុខសង្គម, និងក្រុមហ៊ុនធានារ៉ាប់រង ជ្រាបថា អនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ និងក្របខណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈធនាគារជាតិនៃកម្ពុជា ជាអាណត្តិគាហក នឹងធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង ក្នុងទំហំ **១ ២១៩ ៥០០ ០០០ ០០០** (មួយទ្រីលាន ពីររយដប់ប្រាំបួនប៊ីលាន ប្រាំរយលាន) រៀល សមមូលនឹងប្រមាណ ៣០០ ០០០ ០០០ (បីរយលាន) ដុល្លារអាមេរិក ចាប់ពីខែកញ្ញា ឆ្នាំ២០២២ តទៅ ដូចមានព័ត៌មានលម្អិតខាងក្រោម÷

ក) **តម្លៃចារឹកក្នុងមួយប័ណ្ណ÷** ១ ០០០ ០០០ (មួយលាន) រៀល

ខ) **ប្រភេទមូលបត្រ÷** ឥណប្រតិទាន ១ឆ្នាំ, ៣ឆ្នាំ, និង ៥ឆ្នាំ

គ) **ប្រភេទអត្រាគូប៉ុង÷** ថេរ

ឃ) **ការទូទាត់គូប៉ុង÷** រៀងរាល់ ៦ ខែម្តង ដោយគិតចាប់ពីថ្ងៃបោះផ្សាយ

ង) **មូលដ្ឋានរាប់ថ្ងៃ÷** Actual/Actual

ច) **ការសងប្រាក់ដើម÷** ទូទាត់សងនៅចុងឥណប្រតិទាន

ឆ) **វិធីសាស្ត្រ÷** ដេញថ្លៃ

ជ) **កាលវិភាគនៃការបោះផ្សាយ÷**

| ប្រភេទ មូលបត្រ | ទំហំបោះផ្សាយមួយលើកៗ (ប៊ីលានរៀល) | ចំនួនដងនៃការបោះផ្សាយ | គម្លាតនៃការបោះផ្សាយ | ទំហំបោះផ្សាយសរុប (ប៊ីលានរៀល) |
|---|---|---|---|---|
| ឥណប្រតិទាន ១ឆ្នាំ | ១០០ | ២ | ៤សប្តាហ៍ | ២០០ |
| ឥណប្រតិទាន ៣ឆ្នាំ | ២០០ | ៤ | ៤សប្តាហ៍ | ៨០០ |
| ឥណប្រតិទាន ៥ឆ្នាំ | ១០០ | ២ | ៤សប្តាហ៍ | ២០០ |


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ឈ) **ការលើកទឹកចិត្ត÷** វិនិយោគិនមូលបត្ររដ្ឋនឹងទទួលបានការលើកទឹកចិត្ត ដូចខាងក្រោម ÷

១. **ការលើកទឹកចិត្តពន្ធដារ÷** កាត់បន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់បានពីការកាន់កាប់ និង/ឬ ការទិញ-លក់មូលបត្ររដ្ឋ និងលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងជួញដូរមូលបត្ររដ្ឋ សម្រាប់រយៈពេល ៣ឆ្នាំ។

២. **ការលើកទឹកចិត្តក្នុងវិស័យធនាគារ÷** ១) ទទួលស្គាល់ការថ្លឹងហានិភ័យ ០ (សូន្យ) ភាគរយចំពោះមូលបត្ររដ្ឋដែលចារីកជារូបិយវត្ថុជាតិ ឬជារូបិយប័ណ្ណ ក្នុងការគណនាអនុបាតសោធនភាព និង ២) ទទួលស្គាល់ជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ ចំពោះមូលបត្ររដ្ឋដែលចារីកជារូបិយវត្ថុជាតិ ឬជារូបិយប័ណ្ណ ក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាព។

*©ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រក្សាសិទ្ធិក្នុងការកែសម្រួលផែនការបោះផ្សាយនេះ តាមការចាំបាច់៕*